JITCO

# とも

## ～ស្វែងយល់បន្ថែមអំពីប្រទេសជប៉ុន～

មករា 2024 វេដូវរងា

### ប្រធានបទ

យល់ដឹងតាមរយៈតុក្កតាអំពីព្រឹត្តិការណ៍តាមរដូវ ៖ "節分(សិត្សឹប៊ឹន)"

◇~ ចូលឆ្នាំជប៉ុន ~ តោះនាំគ្នាសាកល្បង 書初め(កាគិហ្សុម៉ិ)?　◇កីឡាជាតិជប៉ុន«相撲(ស៊ូម៉ូ)»

កុតឹហ្គុណុម៉ុរិ "ភ្ជាប់ពាក្យនឹងពាក្យ"

### យល់ដឹងតាមរយៈតុក្កតា អំពីព្រឹត្តិការណ៍តាមរដូវ

—節分(សិត្សឹប៊ឹន)—




### ពិធីបុណ្យប្រពៃណីរបស់ជប៉ុន សិត្សឹប៊ឹន

ថ្ងៃទី3 ខែកុម្ភៈគឺជាថ្ងៃសិត្សឹប៊ឹន។ វាជាពិធីបុណ្យមួយដែល គេបាចសណ្ដែកហើយសូត្រថា "អ៊ឹនីវ៉ា សុតុ! ហ្វឹគីវ៉ា អ៊ុឈិ!" ដើម្បីបណ្ដេញវិញ្ញាណអាក្រក់ និង ស្វាគមន៍ឆ្នាំថ្មី។ ញ៉ាំសណ្ដែកតាមអាយុរាប់របស់អ្នក(អាយុបច្ចុប្បន្ន+1)ហើយញ៉ាំ អិហូម៉ាគិ ដោយស្ងៀមស្ងាត់ ហើយបួងសួង។ ញ៉ាំបែរទៅទិសសំណាង (ទិសនាំឱ្យមានសុភមង្គល)។ ទិសសំណាងសម្រាប់ឆ្នាំ2024 គឺ ទិសឦសាន។

"Tomo" ត្រូវបានបោះពុម្ពជាភាសាជប៉ុនមានហ្វឹរិហ្គាណាសំរាប់អាន និង 9ភាសា ទៀត (វៀតណាម ចិន ហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ ខ្មែរ មីយ៉ាន់ម៉ា ម៉ុងហ្គោលី និងអង់គ្លេស) ដើម្បីផ្ដល់ជាព័ត៌មានមានប្រយោជន៍ អំពីការរស់នៅក្នុងប្រទេសជប៉ុន និងការណែនាំគន្លឹះសម្រាប់សិក្សាភាសាជប៉ុន។ កំណែជាភាសាជប៉ុន ត្រូវបានចែកចាយជាខិតប័ណ្ណ ហើយកំណែភាសាបរទេសមានជាទម្រង់ជា PDF នៅលើគេហទំព័រ JITCO ដែលអាចមើលតាមទូរស័ព្ទស្មាតហ្វូន និងឧបករណ៍ផ្សេងៗទៀត។ សូមទាញយកទៅមើលទាំងអស់គ្នា។
(https://www.jitco.or.jp/ja/tomo/)

# ~ ចូលឆ្នាំជប៉ុន ~ តោះនាំគ្នាសាកល្បង 書初め(កាគិហ្សុមិ)?




書初め(កាគិហ្សុមិ)គឺជាពិធីមួយនៅពេលចូលឆ្នាំជប៉ុន គឺការសរសេរអក្សរនិងរូបដំបូងគេនៅដើមឆ្នាំ។ ភាគច្រើនគេសរសេរដោយប្រើទឹកថ្នាំនិងជក់ ដើម្បីសរសេរពាក្យដែលបង្ហាញពីគោលដៅ និងការប្តេជ្ញាសម្រាប់ឆ្នាំថ្មី ឬពាក្យស្លោកដែលបួងសួងសុំសេចក្តីសុខ និងសុភមង្គល។ តោះនាំគ្នាសរសេរគោលដៅសម្រាប់ឆ្នាំនេះ និងក្តីសុបិន ទៅថ្ងៃអនាគត នៅលើក្រដាសធំទាំងអស់គ្នា។



នៅខែមករា យើងបានសាកសួរទៅកាន់បុគ្គល2រូប មកពីវៀតណាម ដែលធ្វើការនៅ ឧស្សាហកម្មអេឡិចត្រូនិចអៃអយ ដែលក្រុមហ៊ុននេះរៀបចំ ពិធីកាគិហ្សុមិជារៀងរាល់ឆ្នាំ។ លោក យ៉ាជិម៉ា ហ្គែនហ្គុ ប្រធានក្រុមហ៊ុនបាននិយាយថា «ក្រៅពិធីកាគិហ្សុមិ យើងមានកម្មវិធីផ្សេងៗពេញមួយឆ្នាំ ដូចជា ពិធីបុណ្យពេញវ័យ ការមើលផ្កាសាគូរ៉ា ការរើសផ្លែស្ត្របឺរី និងការមើលកាំជ្រួច។ បទពិសោធន៍ផ្ទាល់ជាមួយវប្បធម៌ជប៉ុន ធ្វើឱ្យការយល់ដឹងកាន់តែច្បាស់អំពីប្រទេសជប៉ុន និងជួយអ្នកឱ្យការប្រាស្រ័យទាក់ទងគ្នាកាន់តែប្រសើរឡើង។»

សហការដោយ : 相生電子工業株式会社（神奈川県高座郡寒川町）




(សរសេរដោយដៃ)

**■សូមប្រាប់ពីមូលហេតុដែលអ្នកសរសេរ "成長(សេចូ)ការរីកលូតលាស់"**

—ខ្ញុំបានជ្រើសរើសវា ព្រោះរយៈពេល 4 ឆ្នាំហើយ ចាប់តាំងពីខ្ញុំមកប្រទេសជប៉ុន ហើយខ្ញុំមានអារម្មណ៍ថាខ្ញុំរីកចម្រើនដោយសារការសិក្សាផ្សេងៗ។

**■សូមប្រាប់យើងពីចំណាប់អារម្មណ៍របស់ការសរសេរដោយប្រើទឹកថ្នាំ និងជក់**

—វាជាលើកដំបូងរបស់ខ្ញុំដែលប្រើជក់។ ទោះបីជាមានជក់នៅប្រទេសវៀតណាមក៏ដោយ ក៏មិនត្រូវបានគេប្រើជាទូទៅដែរ។ ដំបូងឡើយពិបាកសរសេរព្រោះក្រដាសរហែក។

**■តើអ្វីអ្វីដែលអ្នកសប្បាយឥឡូវនេះ?**

—ខ្ញុំចូលចិត្តធ្វើដំណើរកម្សាន្ត។ នៅពេលដែលខ្ញុំទៅ ស៊ិរ៉ាកាវ៉ាហ្គូ៉ នៅខេត្ត ហ្គិហ្វឺ ខ្ញុំបានរំភើបជាខ្លាំងព្រោះ ខ្ញុំបានឃើញព្រិល។

**■តើអ្នកមានការលំបាកអ្វីទេបន្ទាប់ពីមកប្រទេសជប៉ុន?**

—ខ្ញុំមានអារម្មណ៍ឯកាព្រោះមិនអាចជួបគ្រួសារ។ ឥឡូវនេះ នៅថ្ងៃសម្រាក ខ្ញុំធ្វើការខលហៅជាវីដេអូ ។

**■សូមប្រាប់ពីសុបិន និងគោលដៅរបស់អ្នកទៅថ្ងៃអនាគត**

—ពេលខ្ញុំត្រឡប់ទៅវៀតណាមវិញ ខ្ញុំចង់ធ្វើការដោយប្រើអ្វីដែលខ្ញុំបានរៀននៅប្រទេសជប៉ុន។

**■សូមប្រាប់ខ្ញុំពីមូលហេតុដែលអ្នកសរសេរ "団結(ដាន់កិត្សឺ)ការរួបរួម" ។**

—ខ្ញុំបានជ្រើសរើសពាក្យដែលមានន័យថា មនុស្សជាច្រើនរួមចិត្តរួមថ្លើមគ្នាក្នុងការខិតខំប្រឹងប្រែង សំដៅទៅទិសដៅដូចគ្នា។

**■សូមប្រាប់យើងពីចំណាប់អារម្មណ៍របស់ការសរសេរដោយប្រើទឹកថ្នាំ និងជក់។**

—វាជាលើកដំបូងរបស់ខ្ញុំដែលប្រើជក់។ វាពិបាកណាស់ក្នុងការសរសេរវាឱ្យស្អាត ដូច្នេះខ្ញុំសរសេរសាឡើងវិញច្រើនដង ដោយមើលគំរូ។

**■តើអ្នកធ្លាប់មានអារម្មណ៍រំភើបដែរទេបន្ទាប់ពីមកប្រទេសជប៉ុនទេ?**

—ប្រទេសវៀតណាមមានអាកាសធាតុក្តៅ និងមានភ្លៀងពេញមួយឆ្នាំ ប៉ុន្តែប្រទេសជប៉ុនមានបួនរដូវគឺនិទាឃរដូវ រដូវក្តៅ រដូវស្លឹកឈើជ្រុះ និងរដូវរងា។

**■តើអាហារជប៉ុនអ្វីដែលអ្នកចូលចិត្តជាងគេ?**

—គឺស៊ូស៊ី។ ប៉ុន្តែខ្ញុំមិនពូកែអាហារឆៅទេ។ ខ្ញុំចូលចិត្តណាតូខ្លាំង។

**■សូមប្រាប់ អំពីចំណាប់អារម្មណ៍របស់អ្នកចំពោះប្រទេសជប៉ុនបន្ទាប់ពីបានមកប្រទេសជប៉ុន។**

—ខ្ញុំមកជប៉ុនព្រោះខ្ញុំចូលចិត្តប្រទេសជប៉ុន។ មុនពេលមក ខ្ញុំមិនដែលដឹងថាមានប្រជាជនជប៉ុនជាច្រើនប្រភេទ ដូចជាមនុស្សចិត្តល្អ មនុស្សពិបាក និងមនុស្សដែលតឹងរ៉ឹងចំពោះការងារ នោះទេ។ ពេលខ្លះខ្ញុំមានការងឿងឆ្ងល់ដោយការគិតខុសគ្នាពីជនជាតិវៀតណាម ប៉ុន្តែនៅពេលខ្ញុំរស់នៅទីនេះ ខ្ញុំចាប់ផ្តើមស៊ាំនឹងជនជាតិជប៉ុន និងរបៀបគិតរបស់ពួកគេហើយ។




(សរសេរដោយដៃ)

JITCO មានលក់ "សម្ភារៈសិក្សាភាសាជប៉ុន" ជាច្រើនប្រភេទ។ មានសៀវភៅសិក្សាដែលផ្តោតលើការសន្ទនាដែលប្រើជាទូទៅក្នុងការបណ្តុះបណ្តាលជំនាញ។ សូមពិនិត្យមើលគេហទំព័រ "ហាងអនឡាញលក់សៀវភៅសិក្សា របស់JITCO" ។ https://onlineshop.jitco.or.jp/

## កីឡាជាតិជប៉ុន«**相撲**(ស៊ូម៉ូ)»

相撲(ស៊ូម៉ូ) គឺជាសិល្បៈក្បាច់គុន និងកីឡាប្រកួត តែមួយគត់របស់ប្រទេសជប៉ុន ហើយជាវប្បធម៌ដែលមានប្រពៃណីដ៏យូរលង់។ នេះគេហៅថា «កីឡាជាតិ»។ ដើមកំណើតរបស់វាគឺបុរាណយូរលង់ណាស់ គឺ មានប្រវត្តិចាប់ពី សម័យទេវកថា។

ដំបូងឡើយស៊ូម៉ូ បានរីករាលដាលពាសពេញប្រទេសជប៉ុន ជាពិធីមួយនៃពិធីបុណ្យបួងសួងសុំការប្រមូលផលអោយបានច្រើន។ ម៉្យាងទៀត ក្នុង«សម័យសាមូរ៉ៃ» ចាប់ពីជាង 800 ឆ្នាំមុន ដល់ប្រហែល 400 ឆ្នាំមុន វាត្រូវបានគេអនុវត្តយ៉ាងសកម្ម ជាការហ្វឹកហាត់សម្រាប់ការប្រយុទ្ធ។ បន្ទាប់មកក្នុងសម័យសន្តិភាព «力士(រិគិស៊ិ) អ្នកចំបាប់ស៊ូម៉ូ» អ្នកដែលមានអាជីពជាកីឡាករប្រកួតកីឡា ស៊ូម៉ូ បានបង្ហាញខ្លួន ហើយស៊ូម៉ូ ក៏ចាប់ផ្តើមមានការពេញនិយម ជាការកម្សាន្តមួយដែលត្រូវចំណាយប្រាក់ទើបអាចទស្សនាបាន។

ក្នុងប្រវត្តិដ៏យូរអង្វែងមក ច្បាប់សម្រាប់ជាកីឡាប្រកួតត្រូវបានបង្កើតឡើង ហើយក្នុងពេលជាមួយគ្នានោះ រូបសម្ផស្ស ការរស់នៅប្រចាំថ្ងៃ និង ការប្រាស្រ័យទាក់ទងជាមួយសង្គមរបស់ អ្នកចំបាប់ស៊ូម៉ូ បានក្លាយជាវប្បធម៌ ដែលបន្តរហូតមកដល់សព្វថ្ងៃនេះ។ ឧទាហរណ៍ងាយយល់គឺម៉ូដសក់ដែលមានឈ្មោះថា «ចុងម៉ាហ្គិ» ដែលសក់វែងត្រូវបានចងក្ងួចចុងឡើងលើក្បាលបន្តិច។

មានពាក្យជាច្រើនដែលត្រូវបានប្រើប្រាស់តែនៅក្នុងពិភពនៃ ស៊ូម៉ូ ប៉ុន្តែបានក្លាយជាពាក្យដែលប្រជាជនជប៉ុនតែងតែប្រើជារៀងរាល់ថ្ងៃ។ ឧទាហរណ៍ がちんこ (ហ្គា◌ាជីនកុ) ។ការប្រយុទ្ធដ៏ស្វិតស្វាញត្រូវបានគេហៅថា "ガチの勝負(ហ្គាឈិ ណុស្សូប៊ឺ)ការប្រកួតដ៏ស្វិតស្វាញ" ប៉ុន្តែដើមឡើយវាជាពាក្យប្រើសំរាប់ស៊ូម៉ូ។ ពាក្យបន្ទាប់គឺ 土俵際 (ដុហ្យូហ្គិវ៉ា) ។នៅឆាកប្រកួត ស៊ូម៉ូ មានព្រំដែនរាងជារង្វង់ ហើយប្រសិនបើអ្នកចេញក្រៅពីដែននេះ អ្នកនឹងចាញ់។ ដោយហេតុនេះហើយ ទើបខណៈពេលដែលរឿងអ្វីមួយរៀបនឹងត្រូវបានដោះស្រាយ ឬដល់ទីបញ្ចប់ គេហៅថា ដុហ្យូហ្គិវ៉ា។ ចុងក្រោយគឺពាក្យ 千秋楽（សិនស៊ុរ៉ាគឺ）។ ក្រៅពីស៊ូម៉ូ ពាក្យនេះក៏សំដៅទៅ ថ្ងៃចុងក្រោយនៃការសម្តែង នៃភាពយន្ត និងរឿងល្ខោនជាដើម។ ពាក្យផ្សេងទៀតដូចជា 序ノ口（ចុណុគឺឈិ） 死に体（ស៊ិនិតៃ） 力水（ឈិការា◌៉មិហ្សឺ） 水入り（មិហ្សឺអ៊ិរិ） និង ぶちかまし（ប៊ឺឈិកាម៉ាស៊ិ）ជាដើម មានប្រភពមកពីពាក្យ ប្រើសម្រាប់ស៊ូម៉ូ ។ សាករកមើលអត្ថន័យពាក្យទាំងនេះមើល ប្រហែលជាគួរឱ្យចាប់អារម្មណ៍។

ករណីប្រកួតនៅកីឡាដ្ឋានធំ ដែលត្រូវបានធ្វើឡើងចំនួន 6ដងក្នុងមួយឆ្នាំនៅទីក្រុងតូក្យូ ណាហ្គោយ៉ា អូសាកា និងហ្វូគូអូកា មានគូចំបាប់ច្រើនជាង 100 (ប្រកួត) ក្នុងមួយថ្ងៃ ហើយអ្នកចំបាប់ ស៊ូម៉ូ ម្នាក់ៗប្តូរវេនគ្នាចូលការប្រកួតតែម្តងប៉ុណ្ណោះក្នុងមួយថ្ងៃ និងបន្តរយៈពេល 15ថ្ងៃ។ ប្រព័ន្ធនេះគឺប្លែកខ្លាំងណាស់ សូម្បីតែនៅក្នុងកីឡាជុំវិញពិភពលោកក៏ដោយ។ លើសពីនេះ ដោយការសម្តែងដែលធ្វើឡើងនៅទូទាំងប្រទេស អ្នកចំបាប់ ស៊ូម៉ូ ហាក់ដូចជាមានវត្តមាននៅជិតៗយើង។ ដូច្នេះហើយទើបអ្នកចំបាប់ស៊ូម៉ូត្រូវបានគេហៅថា «お相撲さん(អុស៊ូម៉ូសាន់) បងស៊ូម៉ូ »។ យើងមិនហៅអ្នកលេងកីឡាបេស្បលថា «お野球さん(អូយ៉ាឃ្យឺសាន់)បងយ៉ាឃ្យឺ»ទេ។ មើលការចំបាប់ស៊ូម៉ូ ដែលមានសំឡេងបន្លឺឡើងខ្លាំងដោយសារការប៉ះទង្គិចគ្នា រវាងខ្លួននិងខ្លួន ក្បាលនិងក្បាល ពិតជាអស្ចារ្យណាស់។ កុំភ្លេចសាកល្បងទៅមើលការប្រកួតស៊ូម៉ូ ។



# កុគឺហ្គុណុម៉ុរិ

នេះជាឯកសារសិក្សាសម្រាប់រៀនរបៀបប្រើវាក្យស័ព្ទនិង អក្សរកាន់ជី ភាសាជប៉ុន។ សូមរីករាយក្នុងការគិតរកចម្លើយទាំងអស់គ្នា។

(ចម្លើយមាននៅទំព័របន្ទាប់)




©毎日小学生新聞 ហាមថតចម្លង ឬចែកចាយបន្ត

### មួយសន្លឹកនៃស្នាមញញឹម



សិក្ខាកាមជំនាញស្លៀកសម្លៀកបំពាក់ប្រពៃណីរបស់មីយ៉ាន់ម៉ា ឡុងយី។ រូបថតអនុស្សាវរីយ៍ដែលថតនៅមុខ វត្តអាសាគីសា គឺពោរពេញទៅដោយស្នាមញញឹមស្រស់ស្រាយ ក្រោមមេឃពណ៌ខៀវ។ ថ្ងៃនេះ គាត់បាន ដើរលេងតាមស្ពាននិជីបាស៊ិ មុខបរមរាជវាំងព្រះចៅអធិរាជ ជិះទូកកម្សាន្តនៅ ឈូងសមុទ្រតូក្យូ និង ឃើញ តូក្យូថៅវ៉ឺ និង តូក្យូស្កាយទ្រី ដែលគាត់ចង់ឃើញតាំងពីយូរយារណាស់មក ហើយ និង បានបង្កើតអនុស្សាវរីយ៍ជាច្រើន។

※2023年7月投稿　（監理団体：TNK協同組合、実習実施者：株式会社兼藤）

យើងបានដាក់រូបមួយសន្លឹកនេះដោយបានរើសពី "ទិវាសិក្ខាកាមបណ្តុះបណ្តាលជំនាញ" ដែលបានបង្ហោះ នៅលើគេហទំព័រ JITCOពីសំណាក់អង្គការទទួលសិក្ខាកាមជាដើម។ គេហទំព័រ "ទិវាសិក្ខាកាមបណ្តុះបណ្តាលជំនាញ" និង ពាក្យស្នើសុំអាចមើលនៅទីនេះបាន ។

（https://www.jitco.or.jp/ja/days/）

## ការណែនាំទីប្រឹក្សាយោបល់

**ពេលមានបញ្ហា...?**（https://www.otit.go.jp/notebook/）

នៅ OTIT (អង្គការបណ្តុះបណ្តាលជំនាញបច្ចេកទេសសំរាប់ជនបរទេស) អ្នកអាចប្រើសេវាប្រឹក្សាយោបល់ជាភាសាកំណើតរបស់អ្នក ក្នុងករណីមានបញ្ហា សេវាប្រឹក្សាយោបល់ក្នុងតំបន់ ព័ត៌មានស្តីពីការការពារគ្រោះមហន្តរាយ និងកម្មវិធីទូរស័ព្ទមានប្រយោជន៍ ដូចជា "ភាសាជប៉ុននៅកន្លែងជាក់ស្តែង" និង "សៀវភៅកម្មសិក្សាការហ្វឹកហ្វឺនជំនាញ"។


◆こくごこたえ

ノート と えんぴつ
にこまる の かさ
七時 に おきる
バス が つく
かぜ で 休む
だれ も いない
弟 を わらわせる
どこ へ 行こうか

ある言葉について、さまざまな働きをする小さくて大事な言葉が助詞です。ある言葉の下について、他の言葉との関係を示したり、ある意味を添えたりする働きをします。

ほかにも「から・けれど・こそ・さえ・ほど……」などがあり、言葉の大事なつなぎ手となっています。

និបាតសព្ទជាពាក្យខ្លី ប៉ុន្តែសំខាន់ដែលមានមុខងារផ្សេងៗក្នុងប្រយោគ។ គេប្រើវាភ្ជាប់ពីពាក្យមួយទៅពាក្យមួយទៀត ដើម្បីបង្ហាញទំនាក់ទំនង ឬមានមុខងារបន្ថែមអត្ថន័យជាក់លាក់ណាមួយ។ ឧទាហរណ៍ផ្សេងទៀតរួមមាន «から(ពី)けれど(ទោះបីជា)こそ(ពិតជា)さえ(សូម្បីតែ)ほど(ដល់វិសាលភាពនៃ) ... » ដែលទាំងនេះជាធាតុភ្ជាប់ដ៏សំខាន់នៃពាក្យ។


# とも

*2024年1月　冬季号*

2024年1月1日発行

発　行　公益財団法人 国際人材協力機構（JITCO）
総務部広報室
〒108-0023
東京都港区芝浦2-11-5
五十嵐ビルディング

電　話　03-4306-1166（ダイヤルイン）

JITCO ホームページ　https://www.jitco.or.jp/